ឱម្នាលនៃមនុស្សលោកអើយ! សព្វសាធុការពរដែលបានមកពីព្រះជាម្ចាស់ គឺជាទីកន្លែង ជាផ្ទះសំបែង ជាទីជំរក ជាទីក្រុង ជាដួងចិត្ត ជាព្រៃភ្នំ ក្រំថ្ម ជាទីជំរកជ្រកពួន ជារូងភ្នំ ជ្រោះជ្រលងដងអូរ ជាទឹកដី ជាសមុទ្រ ជាកោះ និង ជាវាលស្មៅដែលព្រះជាម្ចាស់បានបង្កើតមក និង ជាសេចក្ដីសរសើរដ៏រុងរឿងរបស់ទ្រង់។

*-ព្រះបាហាអ៊ូលឡាហ៍*

ឱម្នាលនៃមនុស្សលោកអើយ! អ្នកដឹងហើយថាគ្រប់ទីស្នាក់អាស្រ័យដែលព្រះជាម្ចាស់បានលើកតម្កើង និង អធិដ្ឋានដល់អាណាចក្ររបស់ព្រះជាម្ចាស់ ដែលទីកន្លែងទាំងនោះហើយគឺជាសួនច្បារ និងជាឋានសួគ៌នៃឋានបរមសុខរបស់ព្រះអង្គ ។

*-ព្រះបាហាអ៊ូលឡាហ៍*

***ធម៌អធិដ្ឋានប្រចាំថ្ងៃ***

***(សូត្រមួយថ្ងៃម្ដងចន្លោះពេលថ្ងៃត្រង់ និងពេលល្ងាច)***

បពិត្រព្រះជាម្ចាស់! ទូលបង្គំសូមធ្វើជាសក្ខីភាពថា ព្រះអង្គបានបង្កើតទូលព្រះបង្គំមក ដើម្បីអោយទូលព្រះបង្គំបានស្គាល់និងបូជាសក្ការៈចំពោះព្រះអង្គ ។ ក្នុងខណៈនេះទូលព្រះបង្គំបានជ្រាបហើយនូវភាពទន់ខ្សោយរបស់ទូលព្រះបង្គំ ទៅនឹងបារមីដ៏បវររបស់ព្រះអង្គ និងភាពទន់ខ្សោយរបស់ទូលព្រះបង្គំ ទៅនឹងទ្រព្យសម្បត្តិដ៏ធំធេងរបស់ព្រអង្គ ។ ពុំមានព្រះជាម្ចាស់ដទៃណាទៀតឡើយក្រៅពីព្រះអង្គ ព្រះអង្គទ្រង់ជួយរំដោះទុក្ខភ័យនៃសត្វលោក ព្រះអង្គគង់នៅជានិច្ចដោយបារមីនៃព្រះអង្គឯង ។

*-ព្រះបាហាអ៊ូលឡាហ៍*

ឱព្រះអង្គអើយ! ទូលបង្គំសូមអង្វរលន់តួចំពោះព្រះអង្គសូមព្រះអង្គជួយតាមថែរក្សាទូលព្រះបង្គំ គ្រប់ពេលវេលា និងគ្រប់ស្ថានភាពទាំងអស់ ។

*-ព្រះបាហាអ៊ូលឡាហ៍*

### *ធម៌អធិដ្ឋានសុំការជួយគ្រាទ្រាំ*

តើមានអ្នកកំចាត់ ក្តីទុក្ខវិបត្តិដទៃទៀតឬ? ក្រៅពីព្រះជាម្ចាស់ ។ (ពោល) សូមសេចក្តីសរសើរចូលមានដល់ព្រះអង្គទ្រង់ជាម្ចាស់! យើងខ្ញុំទូលព្រះបង្គំ ទាំងអស់គ្នាជាអ្នកបំរើរបស់ព្រះអង្គ និងជាអ្នកប្រតិបត្តិ ខ្ជាប់តាមព្រះធម្មបញ្ញត្តិរបស់ព្រះអង្គ ។

*-ព្រះបប*

⁂

បពិត្រព្រះជាម្ចាស់! ទូលបង្គំសូមលំអោនកាយថ្វាយបង្គំ ដោយព្រះនាមដ៏បវររបស់ព្រះអង្គ សូមទ្រង់ជួយអោយកិច្ចការនៃអ្នកបំរើរបស់ព្រះអង្គ បានចំរើនរុងរឿងនិងនគរទាំងអស់បានថ្កុំថ្កើងភ្លឺថ្លា ។ ពិតប្រាកដណាស់ព្រះអង្គទ្រង់ប្រកបដោយឫទ្ធានុភាពអស់លើវត្ថុទាំងពួង ។

*-ព្រះបាហាអ៊ូលឡាហ៍*

⁂

"ចូរចេះអត់ធ្មត់នៅគ្រប់ស្ថានភាពទាំងអស់ឡើង និងជឿទុកចិត្តលើព្រះជាម្ចាស់ចុះ" ។

*-ព្រះបាហាអ៊ូលឡាហ៍*

⁂

### *ធម៌អធិដ្ឋានសំរាប់កុមារភាព និងយុវវ័យ*

បពិត្រព្រះជាម្ចាស់! សូមព្រះមេត្តាប្រោសជួយតម្រង់ផ្លូវ និងការពារទូលបង្គំផង សូមអោយទូលបង្គំបានក្លាយជាដួងប្រទីបដ៏ចិញ្ចាចចិញ្ចែង និងជាដួងតារាដ៏ត្រចះត្រចង់ ។ ព្រះអង្គទ្រង់ប្រកបដោយឫទ្ធានុភាព និងពោរពេញទៅដោយពលានុភាព ។

*-សម្តេចអាប់ឌុលបាហា*

⁂

### *ធម៌អធិដ្ឋានសំរាប់ការខមាទោស*

ឱព្រះអង្គម្ចាស់! ព្រះអង្គដ៏រុងរឿង! ព្រះអង្គរមែងលើកលែងទោសដល់អ្នកបំរើរបស់ព្រះអង្គ នៅពេលដែលពួកគេលន់តួដល់ព្រះអង្គ ។

*-ព្រះបប*

⁂